ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការក្រសួងយុត្តិធម៌

លេខ ៨៧១.ថទ.៣.៤១/៩៧

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

ផ្ញើមក

លោក ប្រធានតុលាការគ្រប់ជាន់ថ្នាក់

សូមជ្រាប។

**កម្មវត្ថុ:** អំពីការធ្វើលិខិតថ្កោលទោសនិងបញ្ជីស្រង់ស្ថិតិសាលក្រម សាលដីកាព្រហ្មទណ្ឌស្ថាពរ ឬសេចក្តីចម្លងសាលក្រម សាលដីកាព្រហ្មទណ្ឌស្ថាពរ ។

ខ្ញុំសូមជម្រាបលោកថា កន្លងមកមានតុលាការខ្លះដូចជាតុលាការខេត្តកំពង់ឆ្នាំងនិងពោធិសាត់ជាដើមបានប្រព្រឹត្តបំពានលើមាត្រា១២នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលដោយហ៊ានចេញ លិខិតថ្កោលទោសខុសពីសមត្ថកិច្ចដែលច្បាប់បានកំណត់ ។

តុលាការមួយមិនអាចដឹងអំពីសាលក្រមព្រហ្មទណ្ឌសម្រេចដោយតុលាការឯទៀតទូទាំងប្រទេសនោះទេ ។ មានតែនាយកដ្ឋានព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ទេ ដែលមានបញ្ជីសាលក្រមព្រហ្មទណ្ឌទូទាំងប្រទេសអាចដឹងថាជនណាខ្លះត្រូវបានតុលាការផ្តន្ទាទោស ។

អាស្រ័យដោយក្រសួងត្រូវការធ្វើបញ្ជីសាលក្រមទូទាំងប្រទេសនេះហើយ បានជាក្រសួងបានទាមទារឱ្យតុលាការទូទាំងប្រទេសធ្វើបញ្ជីស្រង់ស្ថិតិសាលក្រមនិងសាលដីកាព្រហ្មទណ្ឌស្ថាព ចាប់ពីពេលតុលាកើតឡើងរហូតមកដល់ដំណាច់ឆ្នាំ១៩៩៦ និងចម្លងសាលក្រម សាលដីកាព្រហ្មទណ្ឌស្ថាពរចាប់ពីដើមឆ្នាំ១៩៩៧ ផ្ញើមកក្រសួង ។

បញ្ហាធ្វើបញ្ជីស្រង់ស្ថិតិសាលក្រម សាលដីកាព្រហ្មទណ្ឌស្ថាពរ និងចម្លងសាលក្រម សាលដីកាព្រហ្មទណ្ឌស្ថាពរផ្ញើមកក្រសួងយុត្តិធម៌នេះ ក្រសួងបានណែនាំច្រើនលើកច្រើនសាររួចមកហើយ តាមលិខិតលេខ

-១១៦ ថទ-៩៥ ចុះថ្ងៃទី៣១-០១-៩៥

-១០៩៩ រប-៩៥ ចុះថ្ងៃទី០៥-១២-៩៥

-១១៩ ថទ-៩៦ ចុះថ្ងៃទី៣០-០១-៩៦

-១៣៥២-រប-៩៦ ចុះថ្ងៃទី០២-១២-៩៦

ប៉ុន្តែលោកប្រធានតុលាការមួយចំនួននៅតែមិនបានយកចិត្តទុកដាក់អនុវត្តតាមការណែនាំខាងលើនេះទេ ។ នេះជាការមើលស្រាលដែលក្រសួងមិនអាចអត់ឱនឱ្យតទៅទៀតបានឡើយ ។ បើអស់លោកត្រូវការបុគ្គលិកជួយការងារថែមទៀត ក្រសួងនិងផ្តល់ក្រមខណ្ឌបន្ថែមឱ្យ ។ ប៉ុន្តែកុំមានៈចិញ្ចឹមទុកការខ្វះខាតនេះតទៅទៀត ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្គួន**